Khmer



# មិនគួរទុកចោល
# ទ្រព្យដ៏មានតម្លៃរបស់យើង
# នៅក្នុងឡានឡើយ។

kidsafevic.com.au

# មិនគួរទុកចោលទ្រព្យដ៏មានតម្លៃរបស់យើងនៅក្នុងឡានឡើយ។

ការទុកចោលក្មេងនៅក្នុងឡានឱ្យនៅតែម្នាក់ឯង ទោះជាក្នុងថ្ងៃណាមួយក៏ដោយគឺមានគ្រោះថ្នាក់។ ការនេះរឹតកាន់តែមានគ្រោះថ្នាក់នៅចំថ្ងៃក្តៅ។ វាអាចបណ្តាលឱ្យរងរបួសធ្ងន់ធ្ងរ ឬស្លាប់។ នៅរដ្ឋវិចតូរីយ៉ា នេះគឺជាការប្រឆាំងនឹងច្បាប់ដែលទុកចោលក្មេងនៅក្នុងឡានឱ្យនៅតែម្នាក់ឯង។ ឪពុកម្តាយ ឬអ្នកថែរក្សាអាចប្រឈមនឹងការផាកពិន័យ ឬជាប់ពន្ធនាគាររហូតដល់ទៅប្រាំមួយខែ។

## តើមានហានិភ័យអ្វីខ្លះ?

សូម្បីតែនៅលើថ្ងៃក្តៅល្មមក្តី សីតុណ្ហភាពនៅក្នុងរថយន្តចតអាចឡើងកម្តៅចាប់ពី 20°C ទៅ 30°C ក្តៅជាងនៅក្រៅឡាន។

ក្នុងរយៈពេលប្រាំនាទី សីតុណ្ហភាពនៅក្នុងឡានអាចកើនឡើងទ្វេដង។ ពេលវាមានកម្តៅ 30 អង្សានៅខាងក្រៅ កូនរបស់អ្នកអាចរងទុក្ខវេទនាក្នុងកម្តៅរហូតដល់ទៅ 60 អង្សា។

ខណៈពេលដែលសីតុណ្ហភាពរាងកាយរបស់កូនក្មេងបានកើនឡើងលឿនជាងមនុស្សពេញវ័យពីបី ទៅប្រាំដង ប្រតិកម្មនៃកម្តៅនេះលើរាងកាយកូនក្មេង នឹងកើតឡើងស្ទើរតែភ្លាមៗ។ ការនេះធ្វើឱ្យពួកគេមានហានិភ័យខ្ពស់ នៃជំងឺដាច់សរសៃឈាមខួរក្បាលដោយសារកម្តៅដែលគំរាមកំហែងដល់ជីវិត ការរងរបួសខួរក្បាល ការគាំងបេះដូង និងសួតនិងការកង្វះជាតិទឹកក្នុងដងខ្លួន។

ឡានមានទំហំធំ ឡើងកម្តៅឆាប់រហ័សដូចគ្នានឹងឡានមានទំហំតូចដែរ។ ការបើកបង្អួចចុះបន្តិច មានប្រតិកម្មតិចតួចលើសីតុណ្ហភាពក្នុងឡាន។ ការធ្វើតេស្តបានបង្ហាញថា ពេលណាបើកចំហបង្អួចចុះប្រមាណជា ១០សង្ទីម៉ែត្រ ការនេះជួយកាត់បន្ថយសីតុណ្ហភាពក្នុងឡានត្រឹមតែប្រាំអង្សាប៉ុណ្ណោះ។

**សម្រាប់ព័ត៌មានបន្ថែមអំពីសុវត្ថិភាពក្នុងឡាន សូមបើកចូលវិបសាយ kidsafevic.com.au ក្នុងករណីគ្រាអាសន្ន សូមទូរស័ព្ទ 000**